ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារ/No: D390/1/2/4

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៧១)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 09 / 2010
ម៉ោង (Time/Heure): 10:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ចំពោះមុខ៖ ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ប៉ែន ពេជ្រសាលី

កាលបរិច្ឆេទ៖ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០

---

**សាធារណៈ**

# សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី

---

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**
អៀង សារី

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
នី ចាន់ឌី
Madhev MOHAN
Lima NGUYEN
គឹម ម៉េងឃី

**សហមេធាវីជនត្រូវចោទ**
អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧១)

**លេខ/No: D390/1/2/4**

ម៉ុច សុវណ្ណារី
Elizabeth-Joelle RABESANDRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Françoise GAUTRY
Isabelle DURAND
Christine MARTINEAU
Laure DESFORGES
Ferdinand DJAMMEN

ឡោ ជុនធី

ស៊ិន សុវ៉ន

ហុង គីមសួន

គង់ ពិសី

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOUIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET
Pascal AUBOIN
Ferdinand DJAMMEN-NZEPA
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ

វ៉ែន ពៅ

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧១)

**លេខ**/No: D390/1/2/4

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "**អ.វ.ត.ក**" បានទទួល "បណ្ដឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី" ដែលសហមេធាវីការពារក្ដីរបស់ជនត្រូវចោទ អៀង សារី ("សហមេធាវីការពារក្ដី") បានដាក់កាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ("បណ្ដឹងឧទ្ធរណ៍")[១]។

## I. **ប្រវត្តិនីតិវិធី និងសេចក្ដីសន្និដ្ឋាន**

១. កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញា ("ក.ស.ព" ឬ "សហព្រះរាជអាជ្ញា") បានដាក់ជូនសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នូវដីកាសន្និដ្ឋានស្ថាពរអនុលោមតាមវិធាន៦៦ ក្នុងសំណុំរឿង ០០២ ("ដីកាសន្និដ្ឋានស្ថាពរ")[២]។ នៅវេលាថ្ងៃដដែល ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក បានចេញសេចក្ដីប្រកាសព័ត៌មានមួយជូនដំណឹងដល់សាធារណជនអំពីការដាក់ដីកាសន្និដ្ឋាននេះ[៣]។ ភាគីបានទទួលការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។

២. នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ សហមេធាវីការពារក្ដីបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនូវ "សំណើជាបន្ទាន់របស់លោក អៀង សារី សុំឲ្យមានការបន្ថែមកម្រាស់ទំព័រ និងពេលវេលាកំណត់

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. E.T.C.

---

[១] បណ្ដឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើការនីតិវិធី, ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1 (បណ្ដឹងឧទ្ធរណ៍")។

[២] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ បានដាក់នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ប្រកាសនៅថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០, D390 ("ដីកាសន្និដ្ឋានស្ថាពរ")។

[៣] សេចក្ដីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា, សេចក្ដីរាយការណ៍ព័ត៌មាន អ.វ.ត.ក, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០។

ដើម្បីដាក់ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ ក.ស.ព[៤]។ ចំពោះសំណើនោះ សហមេធាវីការពារក្តីបានបង្ហាញទឡ្ហីករណ៍ដូចខាងក្រោម៖

> "រឿងនេះមិនអាចធ្វើទៅបានឡើយ សម្រាប់ការឆ្លើយតបឲ្យអស់សេចក្តីទៅនឹងសេចក្តីសន្និដ្ឋានដែលមានកម្រាស់ ៩៣១ ទំព័រ, ការវិភាគវាយតម្លៃ និងព្រាងតាក់តែងសេចក្តីឆ្លើយតបមួយដែលមានសំអាងហេតុត្រឹមត្រូវ ហើយធ្វើការបកប្រែសេចក្តីឆ្លើយតបនៅក្នុងរយៈពេលត្រឹមតែ ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីការដាក់ឯកសារ។ យោងទៅតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ក.ស.ច.ស អាចបន្ថែមកម្រាស់ទំព័រកំណត់ ១៥ទំព័រនេះ បាននៅក្នុងកាលៈទេសៈមួយចំនួន។ យោងទៅតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ក.ស.ច.ស អាចបន្ថែមពេលវេលាកំណត់ទៅតាមសំណើសុំរបស់គូភាគីបាន។ ដោយអនុលោមទៅតាមកាតព្វកិច្ចវីរិយភាព(Due Dillgence) ដែលសហមេធាវីការពារក្តីត្រូវគោរពតាមការឆ្លើយតបឲ្យបានពេញលេញអស់សេចក្តី មិនអាចដាក់ជូននៅក្នុងកម្រិត១៥ទំព័រ ហើយក្នុងរយៈពេល១៥ថ្ងៃកំណត់នេះបានឡើយ"[៥]។

៣. នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានបដិសេធសំណើរបស់សហមេធាវីការពារក្តីដោយបានពន្យល់ថា "មើលទៅទំនងជាមានការភាន់ច្រឡំម្តងទៀតហើយ អំពីដំណើរការនៃប្រព័ន្ធនីតិវិធីជាធរមាននៅចំពោះមុខ អ.វ.ត.ក" ហើយ "មិនមានបទប្បញ្ញត្តិណាមួយនៃវិធានផ្ទៃក្នុងចែងពីការឆ្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ"[៦]។

៤. នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានប៉ុនប៉ងដាក់ចម្លើយតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ ("ចម្លើយតបទៅនឹង

---

[៤] សំណើជាបន្ទាន់របស់លោក អៀង សារី សុំឲ្យមានការបន្ថែមកម្រាស់ទំព័រ និងពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់ ក.ស.ព ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០,D390/1 ("សំណើរបស់សហមេធាវីការពារក្តី អៀង សារី")។

[៥] សំណើរបស់សហមេធាវីការពារក្តី អៀង សារី, ទំព័រ១។

[៦] ចម្លើយតបរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទៅនឹងសំណើបន្ទាន់ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ដើម្បីដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានរបស់ កសព របស់លោក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០, D390/1/1 ("ចម្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើរបស់សហមេធាវីការពារក្តី អៀង សារី")។

ដីកាសន្និដ្ឋានស្ពាតរ")[៧]។ នៅក្នុងចម្លើយតបនេះ ដោយបានឃើញនូវការបដិសេធរបស់ ក.ស.ច.ស ចំពោះសំណើសុំបន្ថែមកម្រាស់ទំព័រ និងពេលវេលាកំណត់ សហមេធាវីការពារក្ដីបានបញ្ជាក់ថា "ហេតុដូច្នេះ មេធាវីការពារក្ដីដាក់ចម្លើយតបនេះ នៅក្នុងរយៈពេលកំណត់១៥ថ្ងៃសម្រាប់ធ្វើការឆ្លើយតប" និងពន្យល់ថាខ្លួន "មិនអាចធ្វើតាមការកំណត់ចំនួន ១៥ ទំព័រសម្រាប់ចម្លើយតបបានទេ និងស្នើសុំឱ្យ ក.ស.ច.ស ទទួលយកចម្លើយតបនេះ បើទោះជាវាខុសពីចំនួនទំព័រដែលបានកំណត់ជាធរមានក៏ដោយ ជាផលប្រយោជន៍នៃសមភាពនៃមធ្យោបាយតទល់រឿងក្ដី"[៨]។ សហមេធាវីការពារក្ដីបានពន្យល់ទៀតថា៖

> "សមភាពនៃមធ្យោបាយតទល់រឿងក្ដីនៅក្នុងបរិបទនេះមានន័យថា៖ **ក.** សមភាពដើម្បីឱ្យ ក.ស.ច.ស ទទួលបានប្រយោជន៍ពីសេចក្ដីសន្និដ្ឋានអង្គច្បាប់ពីខាង ក.ស.ព ផង ពីខាងមេធាវីការពារក្ដីផង។ និង **ខ.** សមភាពសម្រាប់លោក អៀង សារី ទាក់ទិននឹងលោក កាំង ហ្គេកអ៊ាវ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើការឆ្លើយតប ទៅនឹងសេចក្ដីសន្និដ្ឋានស្ពាតររបស់ ក.ស.ព នៅក្នុងសំណុំរឿង ០០១។ ចម្លើយតបនេះគ្រាន់តែមានបំណងជួយ ក.ស.ច.ស នៅពេលដែល ក.ស.ច.ស រៀបចំដីកាដំណោះស្រាយ និងបម្រើផលប្រយោជន៍យុត្តិធម៌ប៉ុណ្ណោះ"[៩]។

៥. នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០ ក.ស.ច.ស បានចេញសេចក្ដីជូនដំណឹងមួយអំពីការដាក់ឯកសារមិនពេញលេញពាក់ព័ន្ធនឹងចេតនារបស់សហមេធាវីការពារក្ដី ក្នុងការដាក់ចម្លើយតបទៅនឹងដីកាសន្និ

---

[៧] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ពាតររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្ដីសង្ខេបបន្ថែម ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/1.3 ("ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរ")។ ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរ ត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿងជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងបណ្ដឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

[៨] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរ, ទំព័រ១។

[៩] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរ, ទំព័រ១។

ដ្ឋានស្ថាពរ (“សេចក្តីជូនដំណឹងស្តីពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់”)[១០]។ សេចក្តីជូនដំណឹងនេះមានសំអាងហេតុដូចខាងក្រោម៖

> “តាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេត ក្រឡាបញ្ជី ក.ស.ច.ស សូមជូនដំណឹងមេធាវីការពារក្តីឲ្យបានជ្រាបថា យើងសូមបដិសេធសំណើសុំបន្ថែមកម្រាស់ទំព័ររបស់ពួកគេ តាមហេតុផលដូចខាងក្រោម៖
>
> - ឯកសារនេះ [sic] វែងជាងបួនដង នៃចំនួនទំព័រដែលមានចែងក្នុងមាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ដែលសេចក្តីសន្និដ្ឋានបានគោរពតាម ដែលមេធាវីការពារក្តីបានដាក់ក្នុងសំណុំរឿង ០០១ និងបានយកមកធ្វើជាឯកសារយោង (D96/1 -១២ ទំព័រ)។
> - សំណើនេះពុំបានលើកឡើងអំពីកាលៈទេសៈពិសេសណាមួយឡើយ គ្រាន់តែបានគាំទ្រដល់ការអនុវត្តនីតិវិធីតទល់មុខគ្នា ដែលពុំមានចែងនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ អ.វ.ត.ក ឡើយ ដូចដែល ស.ច.ស. បានបញ្ជាក់រួចហើយ ក្នុងការបដិសេធសំណើមុន (D390/1/1)”[១១]។

៦. នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីជូនដំណឹងស្តីពីការដាក់ឯកសារពុំពេញលេញ[១២] ហើយនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ពួកគេបានដាក់បណ្តឹងឧទ្ធរណ៍។ ភាគីបានទទួលការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នេះ នៅវេលាថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០ ជាមួយនឹងកាលបរិច្ឆេទសម្រាប់ធ្វើការឆ្លើយតបត្រឹមពេលថ្ងៃត្រង់ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០។

---

[១០] សេចក្តីជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់ ផ្ញើពីក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០ (“សេចក្តីជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់”)។

[១១] សេចក្តីជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់។

[១២] សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០ (“សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍”)។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៧. ក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តីបានស្នើឲ្យអង្គបុរេជំនុំជម្រះ ក) ប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍នោះតាមវិធាន២១នៃវិធានផ្ទៃក្នុង ខ) ទុកជាមោឃៈនូវសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍នេះ គ) បង្គាប់ថា ក្រឡាបញ្ជី ក.ស.ច.ស ត្រូវទទួលយកចម្លើយតបដាក់បញ្ចូលទៅក្នុងសំណុំរឿង ហើយ ក.ស.ច.ស ត្រូវយកចម្លើយតបមកពិចារណាជាមួយនឹងដីកាសន្និដ្ឋានស្ថាពរ[១៣]។ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍នេះ អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុង ដោយមានហេតុផលថា "ក.ស.ច.ស បានរំលោភសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ដែលរួមមាន៖ សមភាពនៃមធ្យោបាយតទល់ក្តី ដោយអនុញ្ញាតអោយការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") ដាក់ដីកាសន្និដ្ឋានស្ថាពរដែលមានកម្រាស់ ៩៣១ទំព័រ ដែលមានរៀបរាប់អំពីអ្វីដែល ក.ស.ព យល់ឃើញថាជាច្បាប់ដែលអាចយកមកអនុវត្តបាន ខណៈពេលនោះបានបដិសេធសិទ្ធិមេធាវីការពារក្តី មិនអោយដាក់ចម្លើយតបពេញលេញ ដែលចម្លើយតបនេះមានកម្រាស់ ៦៦ ទំព័រ ខ) ការប្រព្រឹត្តិដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដូចដែលបានបង្ហាញជូនតាមរយៈការប្រៀបធៀបការប្រព្រឹត្តិរបស់ ក.ស.ច.ស មកលើ កាំង ហ្កេកអ៊ាវ នៅក្នុងសំណុំរឿង ០០១ ជាមួយនឹងការប្រព្រឹត្តិមកលើមេធាវីការពារក្តីនៅក្នុងសេចក្តីសម្រេចដែលគេជំទាស់តវ៉ា និង គ) សិទ្ធិក្នុងការត្រៀមរៀបចំកិច្ចការពារក្តីដោយពេញលេញ និងចងក្រងបង្កើតនូវវិទ្ធ័យតាមរយៈការបដិសេធមិនដាក់ចម្លើយតបទៅក្នុងសំណុំរឿង"[១៤]។

៨. នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០ ក.ស.ព បានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ និងសំណើសុំផ្អាកដំណើរការនីតិវិធី" ("ចម្លើយតបរបស់ ក.ស.ព")[១៥]។

---

[១៣] បណ្តឹងឧទ្ធរណ៍, ទំព័រ១៣។

[១៤] បណ្តឹងឧទ្ធរណ៍, ទំព័រ១។

[១៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកចម្លើយតបរបស់មេធាវីការក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសំណើសុំផ្អាកដំណើរការនីតិវិធី, ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០, D390/1/2/2 ("ចម្លើយតបរបស់ ក.ស.ព")។ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី*

ក្នុងចម្លើយតបរបស់ ក.ស.ព សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គបុរេជំនុំជម្រះ "បដិសេធបណ្ដឹងឧទ្ធរណ៍ដោយហេតុថា តាមនីតិវិធីមិនអាចទទួលយកបាន និងគ្មានអង្គសេចក្ដីជាសារធាតុ"[១៦]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា តាមនីតិវិធី សេចក្ដីជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់មិនមែនជា "ដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយពុំអាចប្ដឹងឧទ្ធរណ៍បានឡើយ យោងតាមវិធានផ្ទៃក្នុង[១៧]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វិធានផ្ទៃក្នុងពុំមានចែងអំពីឱកាសរបស់ជនត្រូវចោទក្នុងការឆ្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាទេ[១៨] ហើយសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ ពុំត្រូវបានរំលោភដោយសារអវត្តមាននៃបទប្បញ្ញត្តិនេះឡើយ ដោយហេតុថា ជនត្រូវចោទមានលទ្ធភាពគ្រប់បែបយ៉ាងដើម្បីដាក់សារណារបស់ខ្លួនអំពីអង្គហេតុ អង្គច្បាប់ និងសំណើផ្សេងៗសុំបំពេញកិច្ចស៊ើបសួរក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ហើយពួកគេក៏បានទទួលសិទ្ធិសុំធ្វើមោឃភាព និងប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសកម្មភាពនានារបស់សហចៅក្រមស៊ើបអង្កេត[១៩]។ ពួកគេបានបន្ថែមថា ប្រសិនបើត្រូវបានចោទប្រកាន់ ជនជាប់ចោទនឹងមានឱកាសតវ៉ានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំពីខ្លឹមសារនៃដីកាដំណោះស្រាយ[២០]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបញ្ចប់នូវទឡ្ហីករណ៍របស់ខ្លួនដោយអះអាងថា "ទោះក្នុងកាលៈទេសៈណាក្ដី នេះពុំរាប់ថាជាការរំលោភដំណើរការឡើយ ក្នុងការបង្ខំឲ្យអង្គបុរេជំនុំជម្រះបោះបង់ចោលយុត្តាធិការរបស់ខ្លួន និងផ្អាកកិច្ចដំណើរការនីតិវិធី"[២១]។

៩. នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះ ដោយបានគូសបញ្ជាក់ថា "សេចក្ដីសម្រេចដោយមានសំអាងហេតុលើបណ្ដឹងឧទ្ធរណ៍នេះ នឹងត្រូវចេញប្រកាសនាពេលសមស្របខាងមុខ"។

---

[១៦] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៤។

[១៧] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ១។

[១៨] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ២។

[១៩] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៣។

[២០] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៣។

[២១] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៤។

អង្គបុរេជំនុំជម្រះ * អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

១. ទទួលយកបណ្តឹងឧទ្ធរណ៍។

២. បដិសេធសំណើសុំបើកសវនាការ និងផ្អាកដំណើរការនីតិវិធី ដោយសារមិនមានភាពចាំបាច់។

៣. បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតដាក់ចម្លើយតបចូលទៅក្នុងសំណុំរឿងជាបន្ទាន់"[២២]។

## II. ការទទួលយកបណ្តឹងឧទ្ធរណ៍

១០. សហមេធាវីការពារក្តីសូមសន្និដ្ឋានថា វិធាន២១នៃវិធានផ្ទៃក្នុង "ប្រគល់យុត្តាធិការពីធម្មជាតិទៅឱ្យអង្គបុរេជំនុំជម្រះ ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌"[២៣]។

១១. សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះគឺពុំអាចទទួលយកបានឡើយតាមនីតិវិធី ដោយហេតុថាបណ្តឹងនេះពុំមែនជាបណ្តឹងឧទ្ធរណ៍លើដីកាសម្រេច ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតឡើយ ហើយដូច្នេះទើបគេពុំអាចប្តឹងឧទ្ធរណ៍បាន អនុលោមតាមវិធានផ្ទៃក្នុងឡើយ"[២៤]។ ពួកគេបន្ថែមថា តាមរយៈសកម្មភាពរបស់ពួកគេដែលត្រូវបានជំទាស់ ក្រឡាបញ្ជី

---

[២២] សាលដីកាលើបណ្តឹងឧទ្ធរណ៍ជាបន្ទាន់របស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០, ឯកសារលេខ៖ D390/1/2/3 ("សាលដីកាចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០")។ ដើម្បីជៀសវាងមន្ទិលសង្ស័យ អង្គបុរេជំនុំជម្រះជូនដំណឹងដល់ភាគីទាំងឡាយថា ការប្រើប្រាស់ទម្រង់ខ្លី "ចម្លើយតប" នៅក្នុងសាលដីកាចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ មានន័យដូចគ្នាទៅនឹងទម្រង់ខ្លី "ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ" នៅក្នុងសាលដីការនេះ។

[២៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២។

[២៤] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៥។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C

"គ្រាន់តែបាន "បង្វិលត្រឡប់ទៅវិញ" នូវឯកសារដែលមានការខ្វះខាត ដើម្បីធ្វើការកែតម្រូវឡើងវិញ ដោយឯកសារនេះអាចនឹងត្រូវបានដាក់ពេលក្រោយទៀតក្នុងទម្រង់ត្រឹមត្រូវមួយ។ ឯកសារនោះគឺមិនអាចអនុញ្ញាតឲ្យបាន និងមានការខ្វះខាត។ វាជាឯកសារមួយដែលមានចំនួនហុកសិបប្រាំមួយ (៦៦) ទំព័រ (ច្រើនក្រាស់ក្រែលជាងចំនួនដប់ប្រាំ (១៥) ទំព័រ ដែលសេចក្តីណែនាំអនុវត្តបានអនុញ្ញាត) ហើយវាត្រូវបានដាក់ ថ្វីបើមានការបដិសេធមួយរបស់សហចៅក្រមស៊ើបអង្កេតមិនទទួលយកក៏ដោយ"[២៥]។ សហព្រះរាជអាជ្ញាបន្ថែមថា "វាជាការណ៍មួយដែលគួរឲ្យកត់សម្គាល់ថា ជនត្រូវចោទពុំបានជ្រើសរើសធ្វើការប្តឹងឧទ្ធរណ៍លើដីកាបដិសេធចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១០ នោះទេ"[២៦]។

១២. វិធាន ២១ នៃវិធានផ្ទៃក្នុង៖

"១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំ អនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ច ដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក- ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ ។ នីតិវិធីត្រូវធានាឲ្យបាននូវភាពដាច់ដោយឡែកពីគ្នារវាងអាជ្ញាធរដែលទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរដែលទទួលបន្ទុកការវិនិច្ឆ័យទោស។

ខ- បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត។

គ- អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃ ដំណើរការនីតិវិធីរឿងក្តី។

ឃ- ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោស ដរាប

[២៥] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៦។

[២៦] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៦។

ណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនឹងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

១៣. អង្គបុរេជំនុំជម្រះធ្វើការកត់សម្គាល់ជាបឋមថា បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវបានសរសេរបញ្ជាក់ក្នុងសេចក្តីជូនដំណឹងរបស់ក្រឡាបញ្ជីស្តីពីការដាក់ឯកសារពុំគ្រប់គ្រាន់។ បើទោះបីច្បាប់ជាធរមានពុំផ្តល់សិទ្ធិឱ្យបានជាក់លាក់ដល់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីជូនដំណឹងស្តីពីការដាក់ឯកសារពុំគ្រប់គ្រាន់ក្តី ក៏អង្គបុរេជំនុំជម្រះបានសម្រេចតាមការសន្និដ្ឋានរបស់សហមេធាវីការពារក្តីថា វិធាន២១ តម្រូវថាអង្គបុរេជំនុំជម្រះត្រូវបកស្រាយឱ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ។ ដោយហេតុថានេះគឺជាបញ្ហាមួយ ពាក់ព័ន្ធនឹងគោលការណ៍ "ស្មើភាពចំពោះមុខច្បាប់" និង "សមភាពនៃមធ្យោបាយតទល់រឿងក្តី" ដោយគិតអំពីភារកិច្ចរបស់អង្គជំនុំជម្រះ ដូចមានចែងត្រង់វិធាន២១នៃវិធានផ្ទៃក្នុង និងកាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍នេះ អង្គបុរេជំនុំជម្រះសម្រេចទទួលយកបណ្តឹងឧទ្ធរណ៍នេះ។

## III. **អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍**

១៤. អង្គបុរេជំនុំជម្រះបានយល់ឃើញជាបឋមថា សំណើសុំបើកសវនាការ និងសុំផ្អាកកិច្ចដំណើរការនីតិវិធី មិនមែនជាការចាំបាច់នោះទេ។

១៥. មុនពេលពិចារណាអំពីសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារស្តីពីការស្មើភាពគ្នាចំពោះមុខច្បាប់ អង្គបុរេជំនុំជម្រះត្រូវធ្វើការសម្រេចថាតើសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅក្នុងការទទួលយកការដាក់ឯកសារចម្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា នៅ

00607216



ក្នុងសំណុំរឿង00១ ដែរឬទេ[២៧]។ គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ មិនអាចត្រូវបានបកស្រាយដើម្បីកំណត់ថា ការភ័ន្តច្រឡំនៅក្នុងរឿងក្តីមួយនឹងត្រូវអនុវត្តតាម នៅក្នុងរឿងក្តីមួយទៀតនាពេលអនាគតទេ ទោះបីជាការភ័ន្តច្រឡំនោះផ្តល់ជាប្រយោជន៍ ចំពោះជនត្រូវចោទក៏ដោយ។ ដោយសារហេតុផលខាងក្រោម អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនមែនជាការភ័ន្តច្រឡំនោះទេ ដែលសហចៅក្រមស៊ើបអង្កេតទទួលយកការដាក់ឯកសារនៅក្នុងសំណុំរឿង00១ នោះ។

១៦. ដូចមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC កម្ពុជា")[២៨] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមិនបានចែងដាក់លាក់អំពីសិទ្ធិសម្រាប់ជនត្រូវចោទក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានោះទេ[២៩]។ ទោះបីជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតត្រូវគោរពតាមវិធាន ២១(១)(ក) និងវិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុងដែលបានចែងថា ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ និងថា បុគ្គលទាំងឡាយដែលយល់ឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នានេះមកអនុវត្ត[៣០]។

១៧. នៅពេលអនុម័តមាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ("CPC បារាំង") ដែលដើរតួនាទីជាគំរូសម្រាប់មាត្រា ២៤៦ មិនបានចែងអំពីលទ្ធភាពដែលថាមេធាវីការពាររបស់ជនត្រូវចោទដាក់ការសង្កេត ដើម្បីឆ្លើយតបទៅនឹងការស្នើសុំរបស់

---

[២៧] ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី កាំង ហ្កេកអ៊ាវ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២00៨, សំណុំរឿង 00១/១៨00៧-២00៧-អ.វ.ត.ក/ក.ស.ច.ស, D96/1 ("ចម្លើយបតទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង 00១")។

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២៤៦។

[២៩] ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២៤៦។

[៣០] វិធាន ២១(១)(ក) និង ២១(១)(ខ)នៃផ្ទៃក្នុង (វិសោធនកម្មលើកទី៥)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ព្រះរាជអាជ្ញានោះទេ (ដែលជាដីកាសន្និដ្ឋានស្ពាតរ)[៣១]។ ចំណុចនេះបានផ្ទុះបញ្ចាំងពីគំរូប្រព័ន្ធស៊ើបអង្កេតជាប្រពៃណីនៃប្រព័ន្ធច្បាប់ស៊ីវិលនៃប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ចាប់តាំងពីត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៧ ដោយកំណត់ថា ជនត្រូវចោទបែបនេះអាចដាក់ការសង្កេត ដើម្បីឆ្លើយតបទៅនឹងការស្នើសុំរបស់ព្រះរាជអាជ្ញា[៣២]។ វិសោធនកម្មនេះត្រូវបានធ្វើឡើងចំពោះក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដើម្បីធ្វើឱ្យមានតុល្យភាពរវាងភាគីនានានៅក្នុងដំណាក់កាលស៊ើបសួរ។ ការតម្រូវឱ្យមានតុល្យភាពនៅដំណាក់កាលស៊ើបសួរនេះ បានធ្វើឱ្យប្រព័ន្ធស៊ើបអង្កេតនៃប្រព័ន្ធច្បាប់ស៊ីវិលទទួលបានការគោរព ដោយសារតែសេចក្តីត្រូវការធ្វើការពិចារណា អំពីសិទ្ធិរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[៣៣]។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនទាន់ត្រូវបានធ្វើវិសោធនកម្មចំណុចនេះនៅឡើយទេ។ ទោះបីជាយ៉ាងណាក៏ដោយគោលការណ៍ទូទៅនៃសមភាពនៃមធ្យោបាយតទល់ក្នុងរឿងក្តី គឺជាការការពារមួយដ៏សំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយអង្គបុរេជំនុំជម្រះបានជឿជាក់ថា សេចក្តីសម្រេចធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងការទទួលយកចម្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ពាតររបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០១ មិនមែនជាការភ័ន្តច្រឡំទេ។

១៨. អង្គបុរេជំនុំជម្រះមិនបានជឿជាក់តាមហេតុផលផ្សេងៗ ដែលបានផ្តល់ឱ្យនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងនៅក្នុងចម្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តីពាក់ព័ន្ធនឹងដំណាក់កាលត្រឹមត្រូវសម្រាប់ការអនុវត្ត "ការពិភាក្សាតទល់គ្នា [ដែលជា] លក្ខណៈនៃការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌" និងផលប៉ះពាល់លើជនត្រូវចោទដែលកើតចេញពីការបដិសេធចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ពាតរ[៣៤]។ អង្គបុរេជំនុំជម្រះទទួលស្គាល់ថា

---

[៣១] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា១៧៥។

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា១៧៥។

[៣៣] សូមមើល ច្បាប់លេខ ២០០៧-២៩១ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ ដែលមាននិន្នាការពង្រឹងតុល្យភាពនៃនីតិវិធីព្រហ្មទណ្ឌ, ជំពូក IV៖ *Dispositions renforçant le caractère contradictoire de la procédure pénale*, មាត្រា១៧៥ កថាខណ្ឌ០៥។

[៣៤] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៣, ចម្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើ[illegible] អៀង សារី។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ប្រសិនបើជនត្រូវចោទត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ការជំនុំជម្រះក្តីនឹងផ្តល់ឱកាសដល់ជនត្រូវចោទក្នុងការជជែកតវ៉ាអំពីការកំណត់បទចោទប្រកាន់ ដូចដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ។ ទោះបីជាយ៉ាងណា វាជាការដែលអាចយល់បានយ៉ាងប្រាកដថា ជនត្រូវចោទអាចចង់ធ្វើសេចក្តីសន្និដ្ឋាន ដើម្បីឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានស្ថាពរដែលត្រូវបានសហចៅក្រមស៊ើបអង្កេតយកទៅពិចារណាមុនពេលចេញដីកាដំណោះស្រាយ ដែលសម្រេចថាតើជនត្រូវចោទប្រឈមនឹងការជំនុំជម្រះក្តីដែរឬទេ និងត្រូវប្រឈមនឹងបទចោទប្រកាន់អ្វីខ្លះ។ លើសពីនេះទៀត មុនពេលដំណាក់កាលសំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក នេះ សហចៅក្រមស៊ើបអង្កេតគ្រាន់តែអាចទទួលប្រយោជន៍ពីការទទួលបានសេចក្តីសន្និដ្ឋានពីសហព្រះរាជអាជ្ញាផង ពីសហមេធាវីការពារក្តីផង។ ការទទួលបានសេចក្តីសន្និដ្ឋានទាំងសងខាងបែបនេះកាន់តែមានសារៈសំខាន់ទៀត ដោយសារសហចៅក្រមស៊ើបអង្កេត មិនត្រូវបានចងកាតព្វកិច្ចដោយដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គភាពតុលាការមិនត្រូវបានចងកាតព្វកិច្ចដោយសេចក្តីសន្និដ្ឋានរបស់ភាគីមួយនោះទេ។ ដូចនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាសន្និដ្ឋានដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា ដែលថាមេធាវីការពារក្តីមិនគួរទទួលបាននូវឱកាសធ្វើការឆ្លើយតប ពីព្រោះដីកាសន្និដ្ឋានស្ថាពរមិនចងកាតព្វកិច្ចលើសហចៅក្រមស៊ើបអង្កេតនោះ មិនអាចធ្វើឱ្យគេជឿជាក់បានទេ[៣៥]។ ជាចុងក្រោយ អង្គហេតុដែលថា មេធាវីការពារក្តីអាចធ្វើបណ្តឹងឧទ្ធរណ៍លើផ្នែកមួយចំនួននៃដីកាដំណោះស្រាយនោះ មិនអាចជំនួសឱ្យសិទ្ធិក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរបានឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីត្រូវបានគំរិតទៅលើបញ្ហាដែលសហមេធាវីការពារក្តីអាចធ្វើបណ្តឹងឧទ្ធរណ៍ ចំពោះដីកាដំណោះស្រាយបាន[៣៦]។

១៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការណែនាំដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ឱ្យ

[៣៥] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ៧។

[៣៦] វិធានផ្ទៃក្នុង (Rev. 5) ៧៤(៣)(ក)។

ក្រឡាបញ្ជីដើម្បីធ្វើការបដិសេធចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនៅក្នុងសេចក្តីជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់នោះ ត្រូវតែពិចារណាដោយគិតដល់ចម្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តីចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ដែលបានបដិសេធជាគោលការណ៍លើសំណើសុំពន្យារពេល និងសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ដោយហេតុថាគ្មានការចែងអំពីចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានៅក្នុងវិធានផ្ទៃក្នុងនោះឡើយ[៣៧]។ ក.ស.ច.ស បានហៅការទំនាក់ទំនងកាលពីមុន ដើម្បីគាំទ្រដល់ការបដិសេធចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនេះថា មិនមានលក្ខណៈគ្រប់គ្រាន់នោះទេ។ ជាដំបូង ក.ស.ច.ស លើកឡើងម្តងទៀតថា ការយល់ព្រមតាមសំណូមពរទាំងនៅក្នុងសំណើសុំរបស់សហមេធាវីការពារក្តី ទាំងនៅក្នុងឯកសារដែលជនត្រូវចោទមានបំណងដាក់អំពីចម្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពរ គឺជាការអនុម័ត "ការអនុវត្តនីតិវិធីតទល់គ្នា" ដែលមិនត្រូវបានចែងនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក នេះទេ"[៣៨]។ បន្ទាប់ពីបានឃើញថាសហចៅក្រមស៊ើបអង្កេតមិនមានកំហុសនៅក្នុងការទទួលយកការដាក់ចម្លើយតប ដោយសហមេធាវីការពារក្តីលោក កាំង ហ្កេកអ៊ាវ នៅក្នុងសំណុំរឿង០០១ ទេនោះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាការបដិសេធជាគោលការណ៍របស់សហចៅក្រមស៊ើបអង្កេតចំពោះការដាក់ចម្លើយតប ទៅនឹងដីកាសន្និដ្ឋានស្ថាពរដែលធ្វើឡើងដោយសហមេធាវីការពារក្តីលោក អៀង សារី ប្រសិនបើបណ្តោយឱ្យធ្វើដូច្នេះ នឹងកើតមាននូវការប្រព្រឹត្តិមិនស្មើភាពគ្នានៅចំពោះមុខច្បាប់ ដែលធ្វើឱ្យមានការខូចខាតដល់ជនត្រូវចោទ អៀង សារី។

២០. បន្ទាប់មកទៀត សេចក្តីជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់បានសន្និដ្ឋានថា សហមេធាវីការពារក្តីខកខានមិនបានលើកឡើងអំពីកាលៈទេសៈពិសេសណាមួយ ដែលធ្វើយុត្តិកម្មដល់ការយល់ព្រមតាមសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហ

[៣៧] ចម្លើយតបរបស់ ក.ស.ច.ស ទៅនឹងសំណើរបស់សហមេធាវីការពារក្តី អៀង សារី។

[៣៨] សេចក្តីជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

មេធាវីការពារក្តីបានធ្វើការពន្យល់ទាំងនៅក្នុងសំណើសុំរបស់ខ្លួន[៣៩] ទាំងនៅក្នុងចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ[៤០]ថា មានកាលៈទេសៈពិសេសដែលធ្វើឲ្យសហមេធាវីការពារក្តីស្នើសុំការអនុញ្ញាតឲ្យដាក់ចម្លើយតបដែលវែងជាងចំនួនទំព័រ ដែលបានអនុញ្ញាតដោយសេចក្តីណែនាំអនុវត្ត។ សហមេធាវីការពារក្តីបានដកស្រង់អង្គហេតុដែលថា ខ្លួនកំពុងធ្វើការឆ្លើយតបទៅនឹងឯកសារចំនួន ៩៣១ ទំព័រ ដែលជាកាលៈទេសៈពិសេសដែលធ្វើឲ្យខ្លួនស្នើសុំបន្ថែមទំព័រសរុបដល់ចំនួន ៧០ ទំព័រ ដើម្បីឆ្លើយតបប្រកបដោយអត្ថន័យពេញលេញទៅនឹងសហព្រះរាជអាជ្ញា និងធ្វើទៅតាមកាតព្វកិច្ចយកចិត្តទុកដាក់ចំពោះជនត្រូវចោទ[៤១]។ នៅក្នុងកាលៈទេសៈទាំងអស់នេះ អង្គបុរេជំនុំជម្រះឯកភាពថា ប្រវែងនៃដីកាសន្និដ្ឋានស្ថាពរគឺជាហេតុផលសមស្របសម្រាប់សហមេធាវីការពារក្តីក្នុងការលើកឡើង ដើម្បីស្នើសុំអនុញ្ញាតដាក់ចម្លើយតបដែលមានចំនួនទំព័រលើសពី ១៥ ទំព័រ។

២១. ដូចដែលបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសេចក្តីជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់នៅក្នុងសំណុំរឿង០០១ សហមេធាវីការពារក្តីលោក កាំង ហ្កេកអ៊ាវ បានដាក់ចម្លើយតបដែលមានចំនួនទំព័រតិចជាង១៥ទំព័រ តបទៅនឹងដីកាសន្និដ្ឋានស្ថាពរដែលមានចំនួន ៨៦ ទំព័រ[៤២]។ សេចក្តីណែនាំអនុវត្ត និងអ្វីៗដែលមានពីមុននៅក្នុងសំណុំរឿង ០០១ ដែលផ្អែកខ្លះត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកធ្វើជាសំអាង មិនបែងចែកភាពខុសគ្នារវាងឯកសារដែលបានដាក់ និងឯកសារដែលបានដាក់ដើម្បីឆ្លើយតបនោះទេ។ នៅពេលដែលសហព្រះរាជអាជ្ញាមានសិទ្ធិដាក់ដីកាសន្និដ្ឋានស្ថាពរលើសពីចំនួន ១៥ទំព័រ ដែលត្រូវបានទទួលស្គាល់ដោយវិធាន ៦៦ នៃវិធានផ្ទៃក្នុង ការបដិសេធដាច់ខាតចំពោះសំណើសុំធ្វើចម្លើយតបទៅនឹងដីកាសន្និដ្ឋានដែលលើសពីចំនួន១៥ទំព័រ ដែលមិនមែនជាឯកសារដែលត្រូវកំណត់ចំនួនទំព័រនោះ គឺជាការមិនអើពើលើអង្គហេតុដែលថា ដីកាសន្និដ្ឋានស្ថាពរមិនដូចជាឯកសារផ្សេងទៀតដែលដាក់នៅចំពោះមុខ អ.វ.ត.ក ទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សហមេធាវីការពារក្តីបានកំណត់យ៉ាងច្បាស់លាស់ អំពី

[៣៩] សំណើរបស់សហមេធាវីការពារក្តី អៀង សារី, ទំព័រ១។

[៤០] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ, ទំព័រ១។

[៤១] សំណើរបស់សហមេធាវីការពារក្តី អៀង សារី, ទំព័រ១។

[៤២] សេចក្តីជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងមានលក្ខណៈមិនគ្រប់គ្រាន់។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

កាលៈទេសៈពិសេស ដែលខ្លួនមានបំណងដាក់ចម្លើយតបវែងជាងទៅនឹងដីកាសន្និដ្ឋានស្ថាពរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពិនិត្យមើលទៅលើកាលៈទេសៈពិសេសទាំងអស់នេះ ការបន្ថែមចំនួនទំព័រដែលបានស្នើសុំមានលក្ខណៈសមស្រប និងត្រូវបានអនុញ្ញាត។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងការណែនាំក្រឡាបញ្ជី សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គហេតុ នៅក្នុងការលើកឡើងថា សហមេធាវីការពារក្តីជនត្រូវចោទខកខានមិនបានលើកឡើង អំពីកាលៈទេសៈពិសេសផ្សេងៗ។

២២. អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ឃើញផងដែរថា ទោះបីជាការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតក្នុងការទទួលស្គាល់ថា សហមេធាវីការពារក្តីអាចធ្វើការឆ្លើយតប និងអាចត្រូវការចំនួនទំព័របន្ថែមផ្អែកតាមកាលៈទេសៈពិសេសក៏ដោយ សហមេធាវីការពារក្តីបានគោរពតាមពេលវេលាកំណត់ដែលបានរៀបរាប់នៅក្នុងវិធានផ្ទៃក្នុង ដូចនេះហើយមិនបានពន្យារកិច្ចដំណើរការនីតិវិធីដោយមិនចាំបាច់ឡើយ។

២៣. ដោយមូលហេតុដូចបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេត បានរំលោភលើការការពារការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ដែលបានផ្តល់ឲ្យដល់ជនត្រូវចោទតាមរយៈវិធាន ២១ នៃវិធានផ្ទៃក្នុង ជាពិសេសដោយសារការខកខានមិនគោរពដល់ការធានាចំពោះជនត្រូវចោទនូវសិទ្ធិទាំងឡាយណាដែលត្រូវបានពណ៌នាជារួមថាជាសមភាពតទល់ក្នុងរឿងក្តី និងការស្មើភាពគ្នាចំពោះមុខច្បាប់។ អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការពិចារណាអំពីមូលដ្ឋានចុងក្រោយនៃបណ្តឹងឧទ្ធរណ៍ ដែលសហមេធាវីការពារក្តីបានលើកឡើងនោះទេ។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

អាស្រ័យដូចមូលហេតុទាំងអស់ដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះសម្រេចសេចក្តីដូចបានប្រកាសនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ**

**Rowan DOWNING នំយ ថុល Catherine MARCHI-UHEL ប៉ែន ពេជ្រសាលី ហ្រ្បាក់ គីមសាន**